ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៧៤៥០ អពដ

រាជធានីភ្នំពេញ ថ្ងៃទី១១ខែ តុលា ឆ្នាំ២០១៧

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការផ្ដល់សេវាទទួលប្រាក់ពន្ធ-អាករ នៅធនាគារកម្ពុជាសាធារណៈ

ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការផ្ដល់សេវាបង់ពន្ធ-អាករឱ្យកាន់តែមានគុណភាព, សុវត្ថិភាព, តម្លាភាព, ភាពងាយស្រួល និងឆាប់រហ័ស សមស្របទៅនឹងសេចក្ដីត្រូវការរបស់អ្នកជាប់ពន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារកម្ពុជាសាធារណៈ សម្រាប់ប្រតិបត្តិការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទ អនុវត្តនៅទូទាំងប្រទេស។

អគ្គនាយកដ្ឋានពន្ធដារ សូមជម្រាបជូនឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស អ្នកជាប់ពន្ធទាំងអស់ មេត្តាជ្រាបថា ដោយសារមានបញ្ហាបច្ចេកទេសខាងផ្នែកប្រព័ន្ធព័ត៌មានវិទ្យារបស់ធនាគារកម្ពុជាសាធារណៈ ជាហេតុធ្វើឱ្យធនាគារនេះ អាចដំណើរការបានត្រឹមតែផ្ដល់នូវសេវាទទួលប្រាក់**ពន្ធលើអចលនទ្រព្យ** នៅតាមសាខាធនាគាររាជធានី ខេត្តប៉ុណ្ណោះ។ ចំពោះការផ្ដល់សេវាទទួលប្រាក់ពន្ធ-អាករប្រភេទផ្សេងទៀត ក្នុងនោះរួមទាំងពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ នៅមិនទាន់បានចាប់ផ្ដើមដំណើរការនៅឡើយ។

ដូច្នេះ ក្នុងអំឡុងពេលដែលប្រព័ន្ធព័ត៌មានវិទ្យារបស់ធនាគារខាងលើ មិនទាន់ដាក់ឱ្យដំណើរការសម្រាប់ផ្ដល់សេវាទទួលប្រាក់ពន្ធផ្សេងៗទៀតបាន និងដើម្បីជៀសវាងធ្វើឱ្យខកខាន ឬរាំងស្ទះក្នុងការបង់ប្រាក់ពន្ធ សូមឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស អ្នកជាប់ពន្ធទាំងអស់ មេត្តាអញ្ជើញទៅបំពេញកាតព្វកិច្ចបង់ពន្ធ នៅតាមធនាគារ ឬសាខាធនាគារ ដែលបានចុះអនុស្សរណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបាននិងកំពុងផ្ដល់សេវាទទួលប្រាក់ពន្ធជូន អគ្គនាយកដ្ឋានពន្ធដារ មានដូចជា **ធនាគារ កាណាឌីយ៉ា អ.ក, ធនាគារ អេស៊ីលីដា ភីអិលស៊ី** និង **ធនាគារ វឌ្ឍនៈ** ជាដើម ឬនៅតាមសាខាពន្ធដាររាជធានី ខេត្ត។

អគ្គនាយកដ្ឋានពន្ធដារ